ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន

លេខ: ១៨........./២០១៧អ.កបធ.សជណ

# សេចក្ដីប្រកាសព័ត៌មាន

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃព្រហស្បតិ៍ **ទី០២ ខែកុម្ភៈ ឆ្នាំ២០១៧** វេលាម៉ោង ១០:០០នាទី នៅសាលប្រជុំអគារ«ស» វិមានរដ្ឋចំការមន ក្រុមប្រឹក្សាធម្មនុញ្ញបានបើកកិច្ចប្រជុំពេញអង្គ ដើម្បីពិនិត្យនិងសម្រេចលើសំណុំរឿង៖

១-លេខ២៧៤/០១២/២០១៧ លេខ២៧៥/០១៣/២០១៧ និងលេខ២៧៦/០១៤/២០១៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ហើយបានចេញសេចក្ដីសម្រេចលេខ១៦៥/០០៥/២០១៧ កបធ.ច ចុះ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧ ដោយបានតម្កល់សេចក្ដីសម្រេចលេខ០២៨ លេខ០២៩ និងលេខ០៣០ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការពេញទាំងមូល។

២-លេខ២៧៧/០១៥/២០១៧ លេខ២៧៨/០១៦/២០១៧ លេខ២៧៩/០១៧/២០១៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ហើយបានចេញសេចក្ដីសម្រេចលេខ១៦៦/០០៦/២០១៧ កបធ.ច ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧ ដោយបានតម្កល់សេចក្ដីសម្រេចលេខ០៣៥ លេខ០៣៦ លេខ០៣៧ លេខ០៣៨ និងលេខ០៤០ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ និងសេចក្ដីសម្រេចលេខ ០៩៥ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល។

៣-លេខ២៨០/០១៨/២០១៧ លេខ២៨១/០១៩/២០១៧ និងលេខ២៨២/០២០/២០១៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ហើយបានចេញសេចក្ដីសម្រេចលេខ១៦៧/០០៧/២០១៧ កបធ.ច ចុះ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧ ដោយបានតម្កល់សេចក្ដីសម្រេចលេខ០៣២ និងលេខ០៣៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការពេញទាំងមូល និងតម្កល់សេចក្ដីសម្រេចលេខ០៣៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មា-ធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការ តែបដិសេធចោលការរក្សាឈ្មោះ **អ៊ូ ចាន់ធី** ដែលពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូងនៃសង្កាត់ផ្សារកណ្ដាលទី២ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូមសាធារណជនជ្រាប។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២៦ ០៣១. E-mail: sgccc@online.com/ info@ccc.gov.kh, Website :http://www.ccc.gov.kh